ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៣៨០០/១៦.ក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌជ្រើសរើស
## ឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ សម្រាប់ឆ្នាំ២០១៦

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.តត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- យោងតាមសំណូមពរចាំបាច់

## សម្រេច

**ប្រការ ១._**

ត្រូវបានបើកឲ្យមានការប្រឡងជ្រើសរើសបេក្ខជនចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ សម្រាប់ឆ្នាំ២០១៦ ដើម្បីបំពេញតម្រូវការរបស់ ក្រសួងមហាផ្ទៃ ។

**ប្រការ ២._**

លក្ខខណ្ឌទូទៅ នៃជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិត្រូវបានកំណត់ដូចខាងក្រោម៖

១-ការប្រឡងជ្រើសរើសឲ្យចូលជានាយនគរបាល ត្រូវជ្រើសរើសចេញពីបេក្ខជនទាំងពីរភេទដែលមានសញ្ញាបត្របរិញ្ញា ឬសញ្ញាបត្រមានតម្លៃស្មើ ឬខ្ពស់ជាងត្រូវមានអាយុយ៉ាងច្រើន ៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ។/

២-ការប្រឡងជ្រើសរើសឲ្យចូលជានាយរងនគរបាល ត្រូវជ្រើសរើសចេញពីបេក្ខជនទាំងពីរភេទ ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ឬសញ្ញាបត្រក្រោមមធ្យមសិក្សាទុតិយភូមិ ត្រូវមានអាយុយ៉ាងច្រើន ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង។

**ប្រការ៣ ._**

លក្ខខណ្ឌដោយឡែក នៃការប្រឡងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់ និងការិយាល័យជំនាញនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវបានកំណត់ ដូចខាងក្រោម៖

- មានសញ្ញាតិខ្មែរ
- **ចំពោះក្របខ័ណ្ឌមន្ត្រីការិយាល័យជំនាញ** មានសញ្ញាបត្របរិញ្ញា ឬសញ្ញាបត្រមានតម្លៃស្មើ ឬខ្ពស់ជាង និងមានអាយុយ៉ាងច្រើន ៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ឬសញ្ញាបត្របរិញ្ញារង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ និងមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង
- មានជីវប្រវត្តិច្បាស់លាស់ និងមិនដែលបានប្រព្រឹត្តិបទល្មើសនានា
- មានសុខភាពល្អ កាយសម្បទាមាំមួន និងគ្មានជំងឺឆ្លង
- មានកម្ពស់ ១.៦៧ម ឡើង សមាមាត្រទៅនឹងទម្ងន់ពី៥៧-៦៧គ.ក្រ ចំពោះបុរស និងមានកម្ពស់ ១.៥៧ម ឡើង មានទម្ងន់ពី៤៧-៥៧គ.ក្រ ចំពោះនារី
- **ចំពោះមន្ត្រីក្របខ័ណ្ឌប៉ុស្តិ៍នគរបាលរដ្ឋបាល** ត្រូវជ្រើសរើសចេញពីក្នុងចំណោមបេក្ខជនដែលមានទីលំនៅក្នុងឃុំ/សង្កាត់សាមី និងមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬក្រោម មធ្យមសិក្សាទុតិយភូមិ ។ ក្នុងករណីគ្មានបេក្ខជនដាក់ពាក្យ ឬដាក់ពាក្យមិនគ្រប់ចំនួន ត្រូវជ្រើសរើសពីក្នុងចំណោមបេក្ខជនដែលមានទីលំនៅក្នុងស្រុក/ក្រុង/ខ័ណ្ឌ ដែលមានព្រំប្រទល់ជាប់គ្នា។

✱**បញ្ជាក់** ៖ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រ ដែលមានតម្លៃស្មើ ។

**ប្រការ ៤._**

លក្ខខណ្ឌដោយឡែក នៃការប្រឡងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃនាយកដ្ឋានអង្គរក្ស នាយកដ្ឋាននគរបាលការពារ ត្រូវបានកំណត់ដូចខាងក្រោម ៖

- មានសញ្ញាតិខ្មែរ
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ឬសញ្ញាបត្រក្រោមមធ្យមសិក្សាទុតិយភូមិ និងមានអាយុចាប់ពី១៨ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង
- មានជីវប្រវត្តិច្បាស់លាស់ និងមិនដែលបានប្រព្រឹត្តិបទល្មើសនានា
- មានសុខភាពល្អ កាយសម្បទាមាំមួន និងគ្មានជំងឺឆ្លង
- មានកម្ពស់ ១.៧០ម ឡើង សមាមាត្រទៅនឹងទម្ងន់ពី៦០-៧០គ.ក្រ ចំពោះបុរស និងមានកម្ពស់ ១.៦០ម ឡើង មានទម្ងន់ពី៥០-៦០គ.ក្រ ចំពោះនារី ។

**ប្រការ៥.—**

លក្ខខណ្ឌដោយឡែក នៃការប្រឡងជ្រើសរើសបេក្ខជនជាបុរសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃវរសេនាតូចនគរបាលការពារព្រំដែន និងនគរបាលការពារបេតិកភណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ឬសញ្ញាបត្រក្រោមមធ្យមសិក្សាទុតិយភូមិ និងមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង
- មានជីវប្រវត្តិច្បាស់លាស់ និងមិនដែលបានប្រព្រឹត្តិបទល្មើសនានា
- មានសុខភាពល្អ កាយសម្បទាមាំមួន និងគ្មានជំងឺឆ្លង
- មានកម្ពស់ ១.៦៣ម ឡើង សមាមាត្រទៅនឹងទម្ងន់ពី៥៣-៦៣គ.ក្រ ។

**ប្រការ ៦.—**

លក្ខខណ្ឌ នៃការប្រឡងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន ក្រុមប្រឹក្សានីតិកម្ម បណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបានកំណត់ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្របរិញ្ញា ឬសញ្ញាបត្រមានតម្លៃស្មើ ឬខ្ពស់ជាង និងមានអាយុយ៉ាងច្រើន ៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ។ មានសញ្ញាបត្របរិញ្ញារង ឬមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំពោះបេក្ខជនដែលចេះជំនាញបច្ចេកទេសតាមតម្រូវការចាំបាច់ដោយឡែក នៃអង្គភាពសាមី និងមានអាយុចាប់ពី ១៨ឆ្នាំ ដល់៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង
- មានជីវប្រវត្តិច្បាស់លាស់ និងមិនដែលបានប្រព្រឹត្តិបទល្មើសនានា
- មានសុខភាពល្អ កាយសម្បទាមាំមួន និងគ្មានជំងឺឆ្លង
- មានកម្ពស់ ១.៦៧ម ឡើង សមាមាត្រទៅនឹងទម្ងន់ពី៥៧-៦៧គ.ក្រ ចំពោះបុរស និងមានកម្ពស់ ១.៥៥ម ឡើង មានទម្ងន់ពី៤៥-៥៥គ.ក្រ ចំពោះនារី ។

**ប្រការ៧.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨.–**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកសុការ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ